# កូននៃឈើ កូននៃថ្ម

## ដំណើរនៃជំនឿរបស់ជនរួចពីរងគ្រោះ ពីអំពើជួញដូរផ្លូវភេទ

### គម្រោងស្រាវជ្រាវមេអំបៅរយៈពេលវែង

---

គម្រោងស្រាវជ្រាវរបស់អង្គការសម្ព័ន្ធចាប់ដៃអំពីសមាហរណកម្ម

*សិក្សាស្រាវជ្រាវទៅលើវដ្តជីវិតនៃជនដែលត្រូវបានគេ*

*កេងប្រវ័ញ្ច និងជួញដូរផ្លូវភេទនៅក្នុងប្រទេសកម្ពុជា*

**2020**

របាយការណ៍សង្ខេប



សម្ព័ន្ធចាប់ដៃ
CHAB DAI COALITION

បណ្ឌិត ហ្គ្លេន ម៉ាលយ៍ . កញ្ញា លឹម វណ្ណធារី . អ្នកស្រី ញ៉ាញ់ ចន្ថា

# កូនឈើ កូនខ្មែរ

## ដំណើរនៃជំនឿរបស់ជនរួចពីរងគ្រោះ ពីអំពើជួញដូរផ្លូវភេទ

*គម្រោងស្រាវជ្រាវមេអំបៅរយៈពេលវែងអំពី សមាហរណកម្មជនរួចពីរងគ្រោះ*

២០២០

## របាយការណ៍សង្ខេប


**រៀបរៀងដោយ៖** បណ្ឌិត ហ្គ្លេន ម៉ាលយ៍
រួមជាមួយកញ្ញា លឹម វណ្ណធារី និងអ្នកស្រី ញ៉ាញ់ ចន្ថា

ក្រុមការងារគម្រោង
លោក ស្រៀង-ផល្លី លោក អ៊ូ-សុភារ៉ា អ្នកស្រី ភឿក-ផលឡែន កញ្ញា កាំង-ជីមី
និង លោក ជេមស៍-ហាវេយ៍

យើងសូមឧទ្ទិស

របាយការណ៍នេះជាកិត្តិយសដល់

**អ្នកស្រី ស៊ីវ៉ាន ម៉ាយល៍**

ដែលជាស្ថាបនិកនៃគម្រោងស្រាវជ្រាវមេអំបៅរយៈពេលវែង
អំពីសមាហរណកម្មជនរួចពីរងគ្រោះ។

គ្រប់ទាំងលទ្ធផលការងារទាំងអស់នេះ

នឹងមិនអាចសម្រេចបានឡើយ

បើសិនជាមិនមាននូវសេចក្ដីស្រលាញ់

និងការយកចិត្តទុកដាក់យ៉ាងខ្លាំងក្លា

របស់លោកស្រីចំពោះកុមារនៅកម្ពុជា។

SIOBHAN MILES
Memorial Library & Resource Centre

សម្ព័ន្ធចាប់ដៃ
CHAB DAI
COALITION

# សេចក្ដីថ្លែងអំណរគុណ

ការស្រាវជ្រាវនេះអាចធ្វើទៅបានតាមរយៈការគាំទ្រ និងការលះបង់ពីសំណាក់ដៃគូរសហការជាច្រើន។ យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាលក្ខណៈបុគ្គល និងអង្គការទាំងអស់ ដែលចូលរួមក្នុងការសិក្សាមេអំបៅនេះ។ ជាដំបូង យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកចូលរួមនៅក្នុងការស្រាវជ្រាវរបស់យើង ដែលបានចែករំលែករឿងរ៉ាវជីវិត និងបទពិសោធន៍របស់ពួកគេ។ យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមអ្នកស្រាវជ្រាវគម្រោងមេអំបៅ ដែលរួមមានលោក ស្រៀង-ផល្លី អ្នកស្រី គឿក-ផលឡែន លោក អ៊ូ-សុភារ៉ា និងកញ្ញា កាំង-ជីមុំ ចំពោះការលះបង់ខ្ពស់ចំពោះការស្រាវជ្រាវ និងការខិតខំប្រឹងប្រែងដើម្បីប្រមូលទិន្នន័យ ចម្លង និងបកប្រែទិន្នន័យសម្រាប់ការសិក្សាស្រាវជ្រាវមួយនេះ។ សូមថ្លែងអំណរគុណផងដែរចំពោះលោក ដែមស៍-ហាវេយ៍ ទីប្រឹក្សាគម្រោង ដែលបានចូលរួមចំណែកក្នុងគម្រោងស្រាវជ្រាវមេអំបៅ។

យើងសូមថ្លែងអំណរគុណដល់ Equitas ដែលជាម្ចាស់ជំនួយដើមនៃការសិក្សាស្រាវជ្រាវមេអំបៅ សម្រាប់ជំនឿរបស់ពួកគេមកលើការសិក្សា។ យើងក៏សូមថ្លែងអំណរគុណចំពោះ Imago Dei Fund, Love 146, Stronger Together, Tenth Church, Karakin Foundation, Change of Path, ACCI, និងបណ្ដាម្ចាស់ជំនួយដទៃទៀត សម្រាប់ការគាំទ្រផ្នែកហិរញ្ញវត្ថុរបស់ពួកគេ។

យើងខ្ញុំសូមកោតសរសើរចំពោះកម្មវិធីជំនួយនីមួយៗ ដែលបានសហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ ក្នុងការផ្ដល់ឱ្យមានអ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ។ សូមថ្លែងអំណរគុណផងដែរចំពោះកម្មវិធីជំនួយ ដែលបានផ្ដល់ជាមតិយោបល់ ដើម្បីដាក់បញ្ចូលទៅក្នុងលទ្ធផលស្រាវជ្រាវ និងអនុសាសន៍ផ្សេងៗ។

អង្គការ Agape (AIM), អង្គការ ARM, អង្គការ Bloom អាស៊ី, អង្គការ Cambodia Hope Organization (CHO), អង្គការ Citipointe អន្តរជាតិ, អង្គការកូនស្រី, អង្គការសង្គ្រោះជោគវាសនា, អង្គការសួននៃក្ដីសង្ឃឹម, អង្គការហាការកម្ពុជា, មជ្ឈមណ្ឌលថៃទាំសុខភាពសម្រាប់កុមារ (HCC), អង្គការ Hope for Justice Cambodia, អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM), អង្គការ Pleroma Home for Girl, អង្គការ Ratanak អន្តរជាតិ, អង្គការ World Hope, & អង្គការទស្សនពិភពលោក។

លើសពីនេះ យើងសូមថ្លែងអំណរគុណដល់អ្នកស្រី ហៅលែន-ស្វន ជាស្ថាបនិក និងជានាយកអន្តរជាតិនៃអង្គការសម្ព័ន្ធចាប់ដៃ សម្រាប់ទស្សនៈវិស័យ ការណែនាំ និងទឹកចិត្តដ៏មុតមាំចំពោះការស្រាវជ្រាវនេះ។ លោករស់-យ៉េង នាយកប្រចាំប្រទេសនៃអង្គការសម្ព័ន្ធភាពចាប់ដៃ សម្រាប់ការគាំទ្រ និងការលើកទឹកចិត្តរបស់គាត់ និងលោក ខ្វង-គឹមហេង ប្រធានជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុនៃអង្គការសម្ព័ន្ធចាប់ដៃ សម្រាប់កិច្ចខិតខំប្រឹងប្រែងដោយមិនគិតពីការនឿយហត់ក្នុងការរៀបចំខ្ទង់ចំណាយ និងរបាយការណ៍ហិរញ្ញវត្ថុដល់ម្ចាស់ជំនួយ។

រូបភាពគម្របមុខ៖ កញ្ញា កាំង ជីម៉ី
រចនាគម្របមុខ៖ លោក ស្រៀង-ផល្លី និងលោក Paul Austria

TENTH CHURCH Stronger Philanthropy LOVE146 END CHILD TRAFFICKING AND EXPLOITATION imago dei fund

# ទំនាក់ទំនងមកយើងខ្ញុំ

ចាប់តាំងពីឆ្នាំ២០១០ គម្រោងស្រាវជ្រាវមេអំបៅរយៈពេលវែង (BLR) នៃអង្គការសម្ព័ន្ធចាប់ដៃបានធ្វើការតាមដានជីវិតកុមារ និងមនុស្សពេញវ័យដែលជាជនរួចពីរងគ្រោះពីអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ច និង/ឬរំលោភបំពានផ្លូវភេទចំនួន១២៨នាក់។ ការសិក្សានេះចាប់ផ្តើមឡើងក្នុងគោលបំណងស្វែងយល់ថា "តើមានអ្វីខ្លះកើតឡើងចំពោះជនរួចពីរងគ្រោះពីអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ច និង/ឬការរំលោភបំពានបន្ទាប់ពីពួកគេត្រូវបានអង្គការយកទៅរស់នៅក្នុងមណ្ឌល (ក្នុងករណីភាគច្រើន) និងក្រោយពីបានធ្វើសមាហរណ៍កម្មទៅក្នុងសហគមន៍វិញ? តើពួកគេពិតជាមានសេរីភាពដែរ ឬទេ?" ដោយក្រុមការងារគម្រោងមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការផ្តល់នូវកន្លែង សុវត្ថិភាពសម្រាប់ជនរួចពីរងគ្រោះក្នុងការចែករំលែកសំឡេង និងការយល់ឃើញរបស់ពួកគេយ៉ាងជាប់លាប់ ពួកយើងទទួលបានការយល់ដឹងយ៉ាងស៊ីជម្រៅពីតថភាពប្រចាំថ្ងៃរបស់អតិថិជនម្នាក់ៗ ដែលជាអ្នកចូលរួមក្នុងគម្រោងសិក្សានេះ។ វាជាការប្តេជ្ញារបស់ក្រុមការងារ ក្នុងការផ្តល់នូវបទពិសោធន៍ទាំងនេះជូនដល់អ្នកសិក្សា និងមិត្តអ្នកអាន។

ដូច្នេះ យើងសូមលើកទឹកចិត្តដល់ដៃគូពាក់ព័ន្ធទាំងអស់ សូមប្រើប្រាស់របាយការណ៍ ដែលយើងមានជាច្រើននេះ ដើម្បីសិក្សាស្វែងយល់ឲ្យបានទូលំទូលាយថែមទៀត។ រហូតមកដល់ពេលនេះ គម្រោងស្រាវជ្រាវមេអំបៅរយៈពេលវែងបានសរសេររបាយការណ៍ចំនួន១០ ដែលរបាយការណ៍ទាំងនោះនិយាយអំពី ការឆាប់វិលត្រឡប់មកភាពធម្មតាវិញ ការមាក់ងាយ ប្រធានបទពីបទពិសោធន៍ជនរួចពីរងគ្រោះភេទប្រុស ការតបស្នងសងគុណ និងរបាយការណ៍ផ្សេងៗមួយចំនួនទៀត។ សូមចូលទៅស្វែងរកនូវរបាយការណ៍ ដែលយើងបានបោះពុម្ព និងរបាយការណ៍ ដែលយើងនឹងបោះពុម្ពផ្សាយនៅពេលអនាគតឆាប់ៗតាមរយៈអាស័យដ្ឋាន៖ Siobhan Miles Memorial Library & Resource Centre ហើយសម្រាប់ព័ត៌មានបន្ថែមវីដេអូ និងព័ត៌មានថ្មីៗអំពីគម្រោងស្រាវជ្រាវមេអំបៅ សូមចូលទៅមើលនៅលើគេហទំព័រ

www.chabdai.org/butterfly

យើងសូមអរគុណយ៉ាងជ្រាលជ្រៅសម្រាប់ការចំណាយពេលស្តាប់
និងការសិក្សារៀនសូត្រជាមួយពួកយើង។ ក្រុមការងាររបស់យើងសូមស្វាគមន៍រាល់សំណួរ
ការផ្តល់មតិយោបល់ និងការផ្តល់មតិត្រឡប់នានាដោយក្តីរីករាយ។

# សេចក្ដីផ្ដើម

នេះគឺជារបាយការណ៍បច្ចេកទេសស្ដីពីដំណើរនៃសេចក្ដីជំនឿ របស់ជនរួចពីរងគ្រោះពីអំពើជួញដូរផ្លូវភេទពីក្នុងគម្រោងស្រាវជ្រាវមេអំបៅរយៈពេលវែងរបស់អង្គការសម្ព័ន្ធចាប់ដៃ។ អ្នកចូលរួមត្រូវបានគេសួរសំណួរជាច្រើន ទាំងសំណួរបែបគុណវិស័យ (សំណួរទម្រង់បើក) និងសំណួរបែបបរិមាណវិស័យ (សំណួរទម្រង់បិទ) ពី ២ ទៅ ៣ដងក្នុងមួយឆ្នាំៗ។ អត្ថប្រយោជន៍ដ៏សំខាន់មួយនៃវិធីសាស្ត្រស្រាវជ្រាវរយៈពេលវែងនេះ គឺជាការវិវត្តន៍នៃការជឿទុកចិត្ត និងការលាតត្រដាងព័ត៌មានរយៈពេល១០ឆ្នាំ។ ការទាក់ទងជាប្រចាំជាមួយបុគ្គលិកអ្នកស្រាវជ្រាវ ដែលមានការយកចិត្តទុកដាក់ បាននាំមកនូវមិត្តភាពយ៉ាងជ្រាលជ្រៅជាមួយអ្នកចូលរួម។ ជាលទ្ធផល យើងទទួលបាននូវអត្ថប្រយោជន៍ ដែលមិនអាចបដិសេធបាន។ ទោះជាយ៉ាងណាក៏ដោយ ការជឿទុកចិត្តយ៉ាងជ្រាលជ្រៅបានកើតឡើងរវាងអ្នកចូលរួម និងអ្នកស្រាវជ្រាវ មានន័យថាព័ត៌មានដែលទទួលបានគឺជ្រាលជ្រៅ និងពោរពេញដោយអត្ថន័យ និងគំនិតឆ្លុះបញ្ចាំង។ និយាយក្នុងន័យម៉្យាងទៀត វាក៏មានន័យថា ការស្រាវជ្រាវនេះធ្វើឡើងប្រកបដោយក្រមសីលធម៌យ៉ាងច្រើន ព្រោះវាក្លាយជាអ្វីមួយដែលបង្ហាញឱ្យឃើញអំពីការទំនាក់ទំនង ច្រើនជាងការរៀបរាប់ពីការប្រើប្រាស់ឧបករណ៍ផ្សេងៗដើម្បីទទួលបានព័ត៌មាន។

## កម្មវត្ថុនៃរបាយការណ៍នេះគឺដើម្បីស្វែងយល់នូវចំណុចដូចខាងក្រោម៖

១. *តើអ្នកចូលរួមយល់យ៉ាងណាអំពីជំនឿ/ជីវិតផ្នែកព្រលឹងវិញ្ញាណ?*

២. *តើជំនឿ/ជីវិតផ្នែកព្រលឹងវិញ្ញាណរបស់ពួកគេមានឥទ្ធិពលយ៉ាងណាទៅលើជីវិត និងការស្តារនីតិសម្បទាឡើងវិញ?*

៣. *តើជំនឿ/ជីវិតផ្នែកព្រលឹងវិញ្ញាណរបស់ពួកគេមានឥទ្ធិពលយ៉ាងណា ទៅលើទំនាក់ទំនងរបស់ពួកគេ ទៅលើអ្នកដទៃ និងសង្គម?*

# វិធីសាស្ត្រ

ទិន្នន័យនៅក្នុងរបាយការណ៍នេះត្រូវបានប្រមូលមកតាមរយៈកិច្ចសម្ភាសន៍ ដែលទទួលកាលពីឆ្នាំកន្លងៗទៅ ជាពិសេសអ្នកចូលរួមចំនួន ៨៥នាក់ នៅក្នុងឆ្នាំ ២០១៧ ដែលត្រូវបានសាកសួរអំពីជំនឿបច្ចុប្បន្នរបស់ពួកគេ និងឥទ្ធិពលនៃជំនឿនោះទៅលើជីវិតរបស់ពួកគេ។ ព័ត៌មានត្រូវបានបែងចែកជាប្រភេទផ្សេងៗគ្នា ចំពោះបែបផែន និងភាពស្រដៀងគ្នានៅក្នុងការវិភាគទិន្នន័យ។ សម្រង់ពាក្យសម្ដីដែលបានប្រើប្រាស់ គឺត្រូវបានដកស្រង់ឡើងដោយរបៀបនៃការរៀបចំយ៉ាងប្រុងប្រយ័ត្ន ហើយវែងជាង និងពេញលេញជាងការប្រើប្រាស់ធម្មតា។ ខ្ញុំដឹងថា ការស្រាវជ្រាវនេះអាចនឹងត្រូវបានវាយតម្លៃដោយអ្នក ដែលចាត់ទុកថាជំនឿមានសារៈសំខាន់ចំពោះពួកគេ ប៉ុន្តែក៏មានអ្នកផ្សេងទៀតដែលអាចរិះគន់ដល់អង្គការគ្រិស្តបរិស័ទថា អង្គការទាំងនេះកំពុងតែបង្ខិតបង្ខំក្នុងការបញ្ចូលសេចក្ដីជំនឿរបស់ពួកគេទៅឱ្យជនរួចពីរងគ្រោះទាំងនោះ។ លទ្ធផលនៃការស្រាវជ្រាវបានជួយឲ្យអ្នកអានស្ដាប់លឺសំឡេងរបស់ជនរួចពីរងគ្រោះពីអំពើជួញដូរ ដោយគ្មានការរិះគន់ ដូច្នេះពួកគេអាចកំណត់ថាតើពួកគេមានអារម្មណ៍ថា ជនរួចពីរងគ្រោះទាំងនេះទទួលបានការបង្ខិតបង្ខំឬយ៉ាងណា។

# ដែនកំណត់

ដំណើរផ្នែកព្រលឹងវិញ្ញាណរបស់យើងទាំងអស់គ្នាផ្លាស់ប្ដូរគ្រប់ពេលជានិច្ច នៅពេលដែលយើងប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ និងការយល់ដឹងរបស់យើងអំពីឥទ្ធិពលមួយ ដែលមានអំណាចធំជាងជីវិតប្រចាំថ្ងៃរបស់យើង។ វាមិនងាយស្រួលទេក្នុងការរៀបរាប់អំពីផ្នែកព្រលឹងវិញ្ញាណជាពិសេសសម្រាប់អ្នកចូលរួម ដែលមិនមែនជាអ្នកកាន់សាសនាជាអាជីព(បុព្វជិត) និងអាចមិនចេះពាក្យពេចន៍គ្រប់គ្រាន់។ សម្រាប់គ្រិស្តបរិស័ទ ការរៀនអំពីជំនឿរបស់ពួកគេធ្វើឡើងតាមរយៈថ្នាក់បង្រៀនព្រះគម្ពីរ និងនៅក្នុងក្រុមជំនុំ ដែលកើតឡើងច្រើនជាងការរៀនសូត្ររបស់ពុទ្ធបរិស័ទវ័យក្មេង ដូច្នេះពួកគេហាក់ដូចជាអាចពន្យល់អំពីជំនឿរបស់ពួកគេបានល្អជាង។

ប្រសិនបើនេះគឺជាការស្ទង់មតិតែម្ដងចប់ ហើយប្រសិនបើចម្លើយដែលយើងទទួលបាន គឺភ្លាមៗបន្ទាប់ពីពួកគេចាកចេញពីកម្មវិធីថែទាំ យើងអាចនឹងមានការប្រុងប្រយ័ត្នច្រើនជាងនេះ អំពី

មតិយោបល់វិជ្ជមានអំពីបទពិសោធន៍របស់ពួកគេ ប៉ុន្តែចម្លើយភាគច្រើននៅទីនេះ ទទួលបានបន្ទាប់ពីពួកគេបានចាកចេញពីកម្មវិធី ហើយទំនាក់ទំនងដែលពួកគេមានជាមួយអ្នកស្រាវជ្រាវគឺកាន់តែមានភាពរឹងមាំ ទើបធ្វើឱ្យក្រុមអ្នកស្រាវជ្រាវជឿថា ចម្លើយរបស់ពួកគេទំនងជាមានភាពស្មោះត្រង់កាន់តែច្រើន។ អ្នកចូលរួមក៏មិនមានការព្រួយបារម្ភផងដែរ ថានឹងមាននរណាម្នាក់ត្រូវបាត់បង់កិត្តិយស ព្រោះពួកគេយល់ថា ឆ្លងកាត់នូវជំនួបអស់ជាច្រើនឆ្នាំមកនេះ ចម្លើយរបស់ពួកគេគឺត្រូវបានរក្សាទុកជាការសម្ងាត់។

## ផ្នែកព្រលឹងវិញ្ញាណ និងការអភិវឌ្ឍ

ទោះបីជាវាមានសារៈសំខាន់យ៉ាងណាក៏ដោយ របាយការណ៍អំពីការអភិវឌ្ឍ និងការអនុវត្តការងារអភិវឌ្ឍន៍ បានចៀសវាងជាប្រព័ន្ធចេញពីប្រធានបទទាក់ទងនឹងព្រលឹងវិញ្ញាណ។ ការចៀសវាងនេះផ្តល់នូវលទ្ធផលស្រាវជ្រាវដែលមានគុណភាពទាប និងកម្មវិធីដែលមិនសូវមានប្រសិទ្ធភាព ហើយជាចុងក្រោយ វាមិនបានផ្តល់ឱកាសដល់អ្នកចូលរួមឲ្យឆ្លុះបញ្ចាំងពីរបៀប ដែលការអភិវឌ្ឍ និងផ្នែកខាងព្រលឹងវិញ្ញាណរបស់ពួកគេ មានផលប៉ះពាល់ចំពោះគ្នាទៅវិញទៅមកទេ។

អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ (UNCRC) មាត្រា ១៤ (**សេរីភាព**នៃគំនិតសតិសម្បជញ្ញៈ និង**សាសនា**)៖ *"កុមារមាន**សិទ្ធិ**គិត និងជឿលើអ្វីដែលពួកគេចង់ និងប្រតិបត្តិ**សាសនា**របស់ពួកគេ ដរាបណា ពួកគេមិនរារាំងអ្នកដទៃមិនឲ្យរីករាយនឹងសិទ្ធិរបស់ពួកគេ។ ឪពុកម្តាយគួរតែជួយដឹកនាំកូនៗរបស់ពួកគេក្នុងកិច្ចការទាំងនេះ។ អនុសញ្ញាគឺគោរពដល់សិទ្ធិទាំងនេះ។"*

## រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា សាសនារដ្ឋ និងសេរីភាពនៃជំនឿ

***មាត្រា ៤៣៖*** *ប្រជាពលរដ្ឋខ្មែរទាំងពីរភេទត្រូវមានសិទ្ធិទទួលបាន**សេរីភាពនៃជំនឿ**។ សេរីភាពខាងជំនឿសាសនា និងការថ្វាយបង្គំត្រូវបានធានាដោយរដ្ឋក្នុងលក្ខខណ្ឌនៃសេរីភាពនេះ។*

Judith Ennew (2015) បានលើកឡើងថា "ការចិញ្ចឹមបីបាច់ខាងព្រលឹងវិញ្ញាណត្រូវតែជាស្នូលនៃសកម្មភាពផ្នែកជំនឿ ជាជាងការផ្លាស់ប្តូរជំនឿ... សិទ្ធិមនុស្សមួយគឺមិនមែនគ្រាន់តែមានវត្តមាននៃផ្នែកព្រលឹងវិញ្ញាណទេ... ជីវិតផ្នែកព្រលឹងវិញ្ញាណរបស់កុមារក៏មិនត្រូវបានរំលោភបំពាន ឬបង្ខូចតាមរយៈទំនាក់ទំនងដែលត្រួតត្រាដោយអំណាចដែរ"។

# លទ្ធផល

លទ្ធផលបង្ហាញថា អ្នកចូលរួមបានទទួលអត្ថប្រយោជន៍ពីដំណើរផ្នែកព្រលឹងវិញ្ញាណរបស់ពួកគេ ទោះបីជាពួកគេចាត់ទុកថា ពួកគេគឺជាគ្រិស្ទបរិស័ទ ឬពុទ្ធបរិស័ទក៏ដោយ។ ទោះបីជាមានការបកស្រាយអំពីជំនឿមិនត្រឹមត្រូវខ្លះក៏ដោយ ក៏ជំនឿភាគច្រើនស្របជាមួយនឹងការយល់ដឹងផ្នែកវប្បធម៌នៃព្រះពុទ្ធសាសនា និងការយល់ដឹងពីព្រះគម្ពីរនៃជំនឿរបស់គ្រិស្តបរិស័ទ។ មានភស្តុតាងតិចតួចដែលថាកុមារត្រូវបានបង្ខំអោយទទួលយកជំនឿទាំងអស់នៅក្នុងមណ្ឌលថែទាំ ប៉ុន្តែមានភស្តុតាងមួយចំនួន ដែលបង្ហាញថាអ្នកចូលរួមខ្លះបានទទួលការរើសអើង នៅពេលពួកគេត្រលប់ទៅលំនៅដ្ឋានរបស់ពួកគេវិញ ប្រសិនបើសាសនារបស់ពួកគេបានផ្លាស់ប្តូរខុសពីជំនឿប្រពៃណីរបស់គ្រួសារ។ ទិដ្ឋភាពវិជ្ជមានផ្នែកព្រលឹងវិញ្ញាណពិតជាបានជួយដល់ការជាសះស្បើយ ព្រមទាំងការស្តារនីតិសម្បទារបស់ពួកគេ និងជួយឲ្យពួកគេត្រឡប់មកសភាពដើមវិញ។ អ្នកចូលរួមក្នុងការស្រាវជ្រាវចំនួនបួននាក់បានពិពណ៌នាថា ជំនឿបានជួយការពារពួកគេពីការធ្វើអត្តឃាត។ អ្នកចូលរួមជាច្រើនបានពិពណ៌នាថា នៅពេលពួកគេអធិស្ឋានទៅកាន់ព្រះយេស៊ូ ឬព្រះពុទ្ធ ពួកគេបង្កើតជារូបភាពក្នុងចិត្តរបស់ពួកគេ ដូច្នេះពួកគេមានអារម្មណ៍ថា ពួកគេអាចបង្ហាញភាពភ័យខ្លាចនិងការខ្វល់ខ្វាយនៅក្នុងទំនាក់ទំនងនេះ។

អ្នកខ្លះបានពិពណ៌នាជាក់លាក់អំពីការផ្លាស់ប្រែនៃឥរិយាបថរបស់ពួកគេគឺ ពួកគេមិនសូវមានភាពអៀនខ្មាស់ មិនសូវខ្វល់ខ្វាយអំពីអ្វីដែលអ្នកដទៃគិតចំពោះពួកគេ ពួកគេអាចគ្រប់គ្រងអារម្មណ៍បានល្អជាងមុន ពួកគេមានភាពអត់ធ្មត់ជាមួយអ្នកដទៃច្រើន មិនសូវច្រឡើសបើស និងហិង្សាទេ។ អ្នកខ្លះរៀបរាប់ថា ពួកគេមិននិយាយកុហក ហើយពួកគេសុខចិត្តទទួលស្គាល់កំហុសរបស់ខ្លួន ប្រសិនបើពួកគេបានធ្វើខុស ពួកគេមានទំនុកចិត្តលើខ្លួនឯង និងជឿទុកចិត្តលើអ្នកដទៃ។ អ្នកខ្លះពិពណ៌នាថា ពួកគេលែងខ្លាចស្លាប់ទៀតហើយ។

សម្រាប់ពុទ្ធសាសនិក ពួកគេបានពិពណ៌នាថា ជំនឿរបស់ពួកគេបានដឹកនាំពួកគេឲ្យបួងសួងសម្រាប់គ្រួសារ និងចេះធ្វើទាន (ការអោយអ្វីមួយដល់អ្នកផ្សេងទៀត)។ សម្រាប់គ្រីស្ទបរិស័ទ ពួកគេបានរៀបរាប់ថា ជំនឿរបស់ពួកគេបានដឹកនាំពួកគេឱ្យមានចិត្តស្រឡាញ់ និងចេះគោរពដល់អ្នកដទៃ និងមិនរើសអើងពួកគេ។

នៅឆ្នាំ ២០១៧ ចំនួនអ្នកចូលរួមដែលបានចាត់ទុកខ្លួនឯងថាជាគ្រិស្តបរិស័ទ មានចំនួនតិចជាងឆ្នាំ ២០១១ (៨០ ទៅ ៤៧)។ ជនរួចពីរងគ្រោះជាច្រើនបានត្រឡប់ទៅរកជំនឿប្រពៃណីរបស់ពួកគេ នៅក្នុងបរិយាកាសនៃគ្រួសាររបស់ពួកគេវិញ ដែលជាញឹកញាប់ ដោយសារតែវាមានភាពងាយស្រួលធ្វើទៅតាមប្រពៃណីនេះ ឬដោយសារគ្មានក្រុមជំនុំនៅក្បែរពួកគេ។ អ្នកខ្លះមានអារម្មណ៍ថា ពួកគេមានពេលវេលាតិចតួចដើម្បីប្រតិបត្តិជំនឿ ដោយតែពួកគេមានជីវិតដែលមមាញឹក។ ទោះយ៉ាងណាក៏ដោយ អ្នកចូលរួមក្នុងការស្រាវជ្រាវនេះ ជាច្រើននាក់បានទទួលស្គាល់ពីគុណប្រយោជន៍នៃជំនឿគ្រិស្តបរិស័ទ ដែលជួយដល់ដំណើរផ្លូវផ្នែកព្រលឹងវិញ្ញាណរបស់ពួកគេ ហើយអ្នកចូលរួមខ្លះទៀតបានបន្តអធិស្ឋានទៅកាន់ព្រះយេស៊ូ/ព្រះជាម្ចាស់។ អ្នកចូលរួមខ្លះបានមើលឃើញការផ្សារភ្ជាប់គ្នារវាងជំនឿទាំងពីរ ហើយបានទាញយកផលប្រយោជន៍ពីជំនឿទាំងពីរនេះ។ ក៏ប៉ុន្តែ អ្នកចូលរួមខ្លះបានទទួលឥទ្ធិពលយ៉ាងខ្លាំងពីជំនឿគ្រិស្តបរិស័ទ ហើយមានអារម្មណ៍ថា គ្មានអ្វីដែលនឹងធ្វើឱ្យជំនឿរបស់ពួកគេរង្គោះរង្គើរនាពេលអនាគតនោះឡើយ។

# អនុសាសន៍

- កម្មវិធីថែទាំ និងកម្មវិធីសហគមន៍ដែលព្យាយាមផ្តល់ "ការថែទាំគ្រប់ជ្រុងជ្រោយ" ចាំបាច់ត្រូវរួមបញ្ចូលទិដ្ឋភាពនានានៅក្នុងកម្មវិធីរបស់ពួកគេ ដែលទទួលស្គាល់ពីផ្នែកព្រលឹងវិញ្ញាណរបស់អតិថិជនរបស់ពួកគេ។
- គោលនយោបាយគាំពារ ចាំបាច់ត្រូវឆ្លើយតបចំពោះការរំលោភបំពានផ្នែកព្រលឹងវិញ្ញាណ ហើយគ្រប់បុគ្គលិកផ្នែកថែទាំទាំងអស់ ត្រូវតែយល់ដឹងអំពីគោលនយោបាយនេះ ហើយចុះហត្ថលេខាលើវា។
- បុគ្គលិកថែទាំមិនត្រូវបង្កើត ឬបង្ហាញអំពីវប្បធម៌ណា ដែលមិនអាចទ្រាំទ្រចំពោះជំនឿផ្សេងៗនោះទេ។
- បុគ្គលិកថែទាំត្រូវលើកទឹកចិត្តអោយជនរួចពីរងគ្រោះជ្រើសរើស និងអនុវត្តសេចក្តីជំនឿ និងកិច្ចការផ្នែកព្រលឹងវិញ្ញាណរបស់ពួកគេដោយសេរី។
- ជនរួចពីរងគ្រោះគួរតែមានសេរីភាពក្នុងការសួរសំណួរពិបាកៗផ្នែកជំនឿ អំពីការរងទុក្ខលំបាករបស់ពួកគេ របស់អ្នកដទៃ និងអំពីអំពើប្រល័យពូជសាសន៍របស់ខ្មែរក្រហម។